ប៉ុស្តឹ ហិរញ្ញវត្ថុ និងធានារ៉ាប់រង

ថ្ងៃពុធ ទី៣០ ខែមិថុនា ឆ្នាំ២០២១ | WWW.POSTKHMER.COM

ដំណោះស្រាយបច្ចេកវិទ្យា
ឌីជីថលនៅកម្ពុជា
រចាយការណ៍ពិសេស

ភ្នំពេញ ប៉ុស្តឹ

TEL: 023 888 161 & 162 // EMAIL:ADVERTISING@PHNOMPENHPOST.COM

FOLLOW US ON

មកដល់បច្ចុប្បន្នព្រូដិនសលកម្ពុជាបានលក់ចេញនូវបណ្ណសន្យារ៉ាប់រងជាង ៣០០,០០០ បណ្ណ។ Supplied



ចាប់តាំងពីការចាប់ផ្តើមអាជីវកម្មព្រូដិនសលកម្ពុជាបានអនុម័តផ្តល់សំណងជូនអតិថិជនជាង១២លានដុល្លារ។

ការគិតគូរឡើងវិញលើការថែទាំសុខភាព និងបរិយាបន្នហិរញ្ញវត្ថុនៅកម្ពុជា

បទសម្ភាសជាមួយ លោក SANJAY CHAKRABARTY អគ្គនាយកក្រុមហ៊ុនព្រូដិនសលកម្ពុជា

Q តើលោកអាចប្រាប់យើងបន្តិចអំពីព្រូដិនសលកម្ពុជាបានទេ?

ក្រុមហ៊ុនព្រូដិនសលកម្ពុជា បានចាប់ផ្តើមអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា ក្នុងខែមករា ឆ្នាំ២០១៣ ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងស្រុងរបស់ក្រុមហ៊ុនព្រូដិនសល ភីអិលស៊ី ដែលជាក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត និងក្រុមហ៊ុនចាត់ចែងទ្រព្យឈានមុខគេនៅអាស៊ី និងអាហ្វ្រិក ក្នុងគោលបំណងជួយឱ្យមនុស្សគ្រប់រូបទទួលបានជីវិតមួយកាន់តែប្រសើរ។

នៅប្រទេសកម្ពុជា យើងសម្រេចគោលបំណងនេះ ដោយផ្តល់ជូនដំណោះស្រាយធានារ៉ាប់រងល្អបំផុត ដើម្បីជួយការពារសុខភាព និងហិរញ្ញវត្ថុជូនប្រជាជន។ មកដល់បច្ចុប្បន្ន យើងបានលក់ចេញបណ្ណសន្យារ៉ាប់រងជាង ៣០០,០០០ បណ្ណ តាមរយៈធនាគារអេស៊ីលីដា ដែលជាធនាគារដៃគូយុទ្ធសាស្ត្រ និងយូរអង្វែង និងទីប្រឹក្សារបស់យើង។ យើងក៏បានអនុម័តផ្តល់សំណងជាង១២លានដុល្លារ ដែលនេះជាសក្ខីភាពនៃការប្តេជ្ញាចិត្តរបស់យើងក្នុងការការពារសុខភាព និងពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុជូនគ្រួសារកម្ពុជា។

ចក្ខុវិស័យរបស់យើង គឺធ្វើឱ្យប្រជាជនកម្ពុជាទាំងអស់អាចមានលទ្ធភាព និងទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យ។ នេះជាការបង្ហាញត្រួសៗ ពីតួនាទីយើងក្នុងនាមជាក្រុមហ៊ុនធានារ៉ាប់រង រាប់ចាប់ពីការផ្តល់ការការពារហិរញ្ញវត្ថុសម្រាប់បុគ្គលម្នាក់ៗ រហូតដល់ផ្តល់ការការពារ និងពន្យារនូវការចាប់ផ្តើមជំងឺផ្សេងៗ។

ចក្ខុវិស័យនេះ ត្រូវបានអនុវត្តនៅក្រុមហ៊ុនទាំងមូល ដែលនាំឱ្យព្រូដិនសលដាក់ចេញកម្មវិធីសុខភាពទូទាំងតំបន់ គឺកម្មវិធី Pulse by Prudential ដែលជាកម្មវិធីសុខភាព និងសុខុមាលភាពលើទូរស័ព្ទ ដំណើរការដោយប្រព័ន្ធបច្ចេកវិទ្យា AI ។

Q តើលោកគិតថាអ្វីទៅជាតួនាទីលើភាពជាដៃគូនៅក្នុងដំណើរឆ្ពោះទៅសម្រេចបេសកកម្មរបស់ក្រុមហ៊ុន?

នៅកម្ពុជា តាមរយៈបណ្តាញទូទាំងប្រទេស និងសាខារបស់ធនាគារដៃគូយើង គឺធនាគារអេស៊ីលីដា យើងអាចធ្វើឱ្យការការពារតាមរយៈសេវាធានារ៉ាប់រងបានទៅដល់ប្រជាជនកម្ពុជាគ្រប់រូប។ នៅសាខាទាំងនេះ អតិថិជនអាចទិញផលិតផលធានារ៉ាប់រងអាយុជីវិត និងសន្សំជាច្រើនប្រភេទដើម្បីជួយធានាដល់អនាគតកូនៗពួកគេ។ យើងក៏កំពុងផ្តល់ការធានារ៉ាប់រងដល់អតិថិជនរបស់ដៃគូយើងផងដែរ។ ជាឧទាហរណ៍ អតិថិជនរបស់ធនាគារអេស៊ីលីដា បានទទួលការការពារឥតគិតថ្លៃចំនួន ៥,០០០ ដុល្លារ លើករណីមរណភាពដោយជំងឺកូវីដ១៩។

លោក SANJAY CHAKRABARTY
អគ្គនាយកក្រុមហ៊ុនព្រូដិនសលកម្ពុជា

ព្រូដិនសលផ្តល់លទ្ធភាពទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យ។

លើសពីនេះ យើងកំពុងធ្វើការជាមួយដៃគូអាជីវកម្ម និងអ្នកផ្តល់សេវាសុខភាពរបស់យើង ដើម្បីផ្តល់ជូននូវសេវាកម្មដែលមានភាពទូលំទូលាយ និងច្នៃប្រឌិតខ្ពស់ដល់ប្រជាជនកម្ពុជា ដែលសេវាកម្មទាំងនេះបានផ្តល់ជូនលើកម្មវិធី Pulse។

Q លោកបានលើកឡើងអំពី Pulse by Prudential ដែលជាកម្មវិធីសុខភាព និងសុខុមាលភាព តើលោកអាចពន្យល់លម្អិតអំពីកម្មវិធីនេះបានទេ?

កម្មវិធី Pulse by Prudential ជាកម្មវិធីសុខភាពឌីជីថលឥតគិតថ្លៃ និងដំបូងគេនៅក្នុងតំបន់ដែលផ្តល់ជូនការគ្រប់គ្រងសុខភាពទូទៅសម្រាប់អ្នកប្រើប្រាស់។ ដំណើរការដោយប្រព័ន្ធបច្ចេកវិទ្យា AI ដែលអាចពិនិត្យព័ត៌មានជាក់ស្តែងបានគ្រប់ពេល ដែលកម្មវិធីនេះជាដៃគូ សុខភាព និង សុខុមាលភាព 24/7 ដល់អ្នកប្រើប្រាស់ ដែលជួយពួកគេទប់ទល់ ពន្យារ និងការពារប្រឆាំងនឹងការចាប់ផ្តើមនៃជំងឺផ្សេងៗ។ យើងបានបើកដំណើរការកម្មវិធីនេះនៅកម្ពុជា នៅខែតុលា ឆ្នាំ២០២០ ។ ចាប់តាំងពីពេលនោះមក កម្មវិធីនេះត្រូវបានទាញយកច្រើនជាង ៧០០,០០០ ដង។ លក្ខណៈពិសេសទាំងអស់របស់ Pulse គឺមានទាំងភាសាអង់គ្លេស និងភាសាខ្មែរ។ Pulse អាចទាញយកបានដោយឥតគិតថ្លៃនៅលើ Google Play និង Apple App Stores។

Q ក្រុមហ៊ុនព្រូដិនសលកំពុងធ្វើការវិនិយោគយ៉ាងច្រើនទៅលើការច្នៃប្រឌិតបច្ចេកវិទ្យា រួមទាំងកម្មវិធី Pulse ។ តើលោកយល់ឃើញថាបច្ចេកវិទ្យាកំពុងផ្លាស់ប្តូររបៀបដែលក្រុមហ៊ុនធានារ៉ាប់រងមានទំនាក់ទំនងជាមួយអតិថិជន និងជះឥទ្ធិពលដល់តួនាទីរបស់ព្រូដិនសលក្នុងនាមជាអ្នកផ្តល់សេវាធានារ៉ាប់រងយ៉ាងដូចម្តេច?

Pulse ជាសមាសធាតុដ៏សំខាន់មួយនៅក្នុងយុទ្ធសាស្ត្រទូទាំងតំបន់របស់ព្រូដិនសល ដើម្បីផ្តល់នូវលទ្ធភាពទទួលបានការថែទាំសុខភាពដែលមានតម្លៃសមរម្យ សម្រាប់ប្រជាជននៅអាស៊ីទាំងមូល ដែលជាតំបន់មានករណីជំងឺរ៉ាំរ៉ៃ និងថ្លៃព្យាបាលសុខភាពចេះតែបន្តកើនឡើង។

ជាមួយកម្មវិធី Pulse ព្រូដិនសលកំពុងបង្កើតប្រព័ន្ធបច្ចេកវិទ្យា AI ផ្តោតសំខាន់លើតម្រូវការអតិថិជនដែលនឹងផ្តល់នូវសេវាកម្មសុខភាព និងសុខុមាលភាពទូលំទូលាយដល់ប្រជាជននៅទូទាំងអាស៊ី។

ខណៈក្រុមហ៊ុនធានារ៉ាប់រងផ្តោតសំខាន់ទៅលើការការពារអតិថិជនប្រឆាំងនឹងហេតុការណ៍អកុសល កម្មវិធី Pulse អនុញ្ញាតឱ្យព្រូដិនសលពង្រីកតួនាទីរបស់ខ្លួន ក្នុងការផ្តល់ការការពារបន្ថែមទៀតនៅគ្រប់ដំណាក់កាលសំខាន់ៗ ផ្នែកសុខភាពរបស់បុគ្គលម្នាក់ៗ។ យើងជឿជាក់ថាក្រុមហ៊ុនធានារ៉ាប់រងអាចដើរតួនាទីការពារបានកាន់តែទូលំទូលាយ ជាមួយនឹងដំណោះស្រាយលើបន្ទុកផ្នែកសុខភាពដែលកំពុងកើនឡើង។

Q តើលក្ខណៈពិសេសអ្វីខ្លះដែលអតិថិជនអាចទទួលបានជាមួយកម្មវិធី Pulse នៅក្នុងប្រទេសកម្ពុជា?

ទាំងនេះជាមុខងារសំខាន់ៗមួយចំនួន លើកម្មវិធី Pulse៖

មុខងារពិនិត្យរោគសញ្ញា (Symptom Checker), មុខងារត្រួតពិនិត្យសុខភាព (Health Check), មាតិកាសុខភាព, ទីតាំងមន្ទីរពេទ្យ, ផលិតផលធានារ៉ាប់រង មូសសុំចាញ់ និងព័ត៌មាន និងការគ្រប់គ្រងបណ្ណសន្យារ៉ាប់រង។

ព័ត៌មានលម្អិតអានតទៅគេហទំព័រ
WWW.POSTKHMER.COM/SPECIAL-REPORT

តើអាជីវកម្មគម្រោងវិនិយោគរួមដំណើរការយ៉ាងដូចម្តេច ?

ទីផ្សារគម្រោងវិនិយោគរួម ឬទីផ្សារមូលនិធិ គឺជាទីផ្សារថ្មីមួយនៅកម្ពុជា ដែលជាច្រកផ្តល់ហិរញ្ញប្បទានយ៉ាងសំខាន់ នៅក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ធំៗ។ អាជីវកម្មគម្រោងវិនិយោគរួម (collective Investment Scheme) គឺជាប្រភេទអាជីវកម្មមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនគ្រប់គ្រងមូលនិធិបង្កើតគម្រោងវិនិយោគដើម្បីប្រមូលមូលនិធិ ឬសាច់ប្រាក់ពី វិនិយោគិនយកទៅវិនិយោគក្នុងគម្រោងដែលបានកំណត់ និងបែងចែកប្រាក់ចំណេញ ឬអត្ថប្រយោជន៍ត្រឡប់មកវិនិយោគិនដែលបានចូលរួមវិញ។

ដើម្បីអាចដំណើរការអាជីវកម្មគម្រោងវិនិយោគរួម ចាំបាច់ត្រូវមានការចូលរួមពីតួអង្គសំខាន់ៗមួយចំនួនដែលមានជាអាទិ៍ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ (Fund Management Company) ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស (Trustee) ក្រុមហ៊ុនចែកចាយលក់ទិញត្រឡប់មកវិញ ឬទូទាត់សង (Distribution Company) និងក្រុមហ៊ុនអភិបាលមូលនិធិ (Fund Administrator)។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ គឺជា

ស្នាក់ការនិយ័តករមូលបត្រកម្ពុជាមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ។ រូបថត ន.ម.ក

តួអង្គចម្បងដែលមានតួនាទីក្នុងការបង្កើតគ្រប់គ្រងនិងចាត់ចែង មូលនិធិ ដើម្បីវិនិយោគក្នុងគម្រោងវិនិយោគណាមួយដែលមានការវិភាគច្បាស់លាស់ និងប្រកបដោយវិជ្ជាជីវៈជំនាញដើម្បីទទួលបានប្រាក់ចំណេញជាអតិបរមាសម្រាប់មូលនិធិក្នុងកម្រិតហានិភ័យទទួលយកបាន។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិអាចបង្កើតមូលនិធិតាមរយៈការបោះផ្សាយលក់ឯកតាមូលនិធិទៅកាន់វិនិយោគិន ដើម្បីធ្វើការប្រមូលសាច់ប្រាក់មកធ្វើការវិនិយោគលើគម្រោងដែលបាន ទទួលការអនុញ្ញាតពី ន.ម.ក។ ការលក់ឯកតាមូលនិធិទៅកាន់វិនិយោគិនត្រូវធ្វើឡើងដោយក្រុមហ៊ុនចែកចាយលក់ទិញត្រឡប់មកវិញឬទូទាត់សង។ ក្រៅពីតួនាទីជាអ្នកជួយលក់ឯកតាមូលនិធិ ក្រុមហ៊ុនចែកចាយលក់ទិញត្រឡប់ មកវិញ ឬទូទាត់សងដែលជាអ្នកបើកគណនីជូនវិនិយោគិន ក៏មានតួនាទីក្នុងការទទួលទិញត្រឡប់មកវិញនូវឯកតាមូលនិធិ ដែលវិនិយោគិនចង់លក់ត្រឡប់ទៅឱ្យមូលនិធិវិញផងដែរ។ តម្លៃនៃឯកតាមូលនិធិ អាចមានការប្រែប្រួលពីមួយថ្ងៃទៅមួយថ្ងៃ ដោយសារតម្លៃនៃទ្រព្យសកម្មរបស់មូលនិធិ អាចមានការប្រែប្រួលហើយ ក្រុមហ៊ុនអភិបាលមូលនិធិគឺជាក្រុមហ៊ុនដែលមានតួនាទីក្នុងការវាយតម្លៃទ្រព្យសកម្មសុទ្ធ និងកំណត់តម្លៃឯកតាមូលនិធិ ផ្ទេរកម្មសិទ្ធិនៃឯកតាមូលនិធិ និងគណនាទ្រព្យសម្បត្តិនៃបរធនវិនិយោគ។

រាល់សាច់ប្រាក់ដែលក្រុមហ៊ុនគ្រប់គ្រងមូលនិធិប្រមូលបានពីវិនិយោគិនតាមរយៈការបោះផ្សាយលក់ឯកតាមូលនិធិនេះ នឹងមិនត្រូវបានរក្សាទុកដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្ទាល់នោះទេ ពោលគឺសាច់ប្រាក់ទាំងនោះនឹងត្រូវរក្សាទុកដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ដែលជាអ្នកតំណាងនៃភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិបរធនវិនិយោគដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ ន.ម.ក។ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ត្រូវតែជាក្រុមហ៊ុនឯករាជ្យពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងត្រូវមានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យ និងតាមដានយ៉ាងសកម្មព្រមទាំងជានាថាប្រតិបត្តិការ និងការគ្រប់គ្រងគម្រោងវិនិយោគរួមរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

គួរបញ្ជាក់ផងដែរថាតួអង្គដូចដែលបានរៀបរាប់ខាងលើ ត្រូវតែជាក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី ន.ម.ក. ដែលជានិយ័តកររនៃវិស័យមូលបត្រក្នុងប្រទេសកម្ពុជា។ គិតមកត្រឹមត្រីមាសទី១ ឆ្នាំ២០២១នេះ ន.ម.ក. បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត ដល់ក្រុមហ៊ុនដូចខាងក្រោម។

សាធារណជនអាចស្វែងរកឈ្មោះក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី ន.ម.ក. តាមរយៈ គេហទំព័ររបស់ ន.ម.ក. ឬតាមរយៈ QR code ដូចមានភ្ជាប់មកជាមួយ៕ ■

ល.រ	អាជីវកម្ម	ចំនួនក្រុមហ៊ុន
១	ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ	៩
២	ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស	១២
៣	ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង	៣
៤	ក្រុមហ៊ុនអភិបាលមូលនិធិ	១

រៀបចំដោយៈ និយ័តកររមូលបត្រកម្ពុជា
នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ
អ៊ីមែលៈ intermediaries@secc.gov.kh
ទូរសព្ទៈ ០២៣ ៨៨៥ ៦១១

ការផ្តោតសំខាន់លើអតិថិជនរបស់ធនាគារ ព្រីនស៍ តាមរយៈសេវាធនាគារឌីជីថល ជួយជំរុញកំណើន

លោក ហ៊ាន់ សុរចនា ប្រធាននាយកប្រតិបត្តិធនាគារ ព្រីនស៍ នៅក្នុងបទសម្ភាសជាមួយកាសែតភ្នំពេញប៉ុស្តិ៍ បានឆ្លុះបញ្ចាំងអំពីវិធីសាស្ត្ររបស់ធនាគារដែលផ្តោតសំខាន់លើអតិថិជន និងការគាំទ្រដល់យុទ្ធសាស្ត្រឌីជីថល និងការពង្រីកវត្តមានរបស់ខ្លួនដើម្បីឆ្លើយតបនឹងតម្រូវការហិរញ្ញវត្ថុដែលកំពុងកើនឡើង។

ធនាគារ ព្រីនស៍ បានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ រូបថត Supplied

Q តើអ្វីជាគោលបំណងនៃការដាក់ឱ្យប្រើប្រាស់កម្មវិធី PRINCE Merchant App និង PRINCE Mobilebiz? តើធនាគារព្រីនស៍ កំពុងពង្រឹងផ្នែកធនាគារសាជីវកម្មរបស់ខ្លួនមែនឬទេ ហើយថាតើអ្នកណាជាអតិថិជនគោលដៅរបស់លោក?

គោលបំណងដែលយើងនឹងដាក់ចេញនូវកម្មវិធីទូរស័ព្ទទាំង២នេះ គឺដើម្បីជួយអតិថិជនសាជីវកម្មរបស់យើងលើការធ្វើអាជីវកម្មបែបឌីជីថលឱ្យកាន់តែមានប្រសិទ្ធភាព ទាំងប្រតិបត្តិការ និងការគ្រប់គ្រង ក៏ដូចជាការភ្ជាប់ប្រតិបត្តិការខាងក្រៅ និងខាងក្នុង របស់ពួកគេឱ្យកាន់តែប្រសើរជាពិសេសក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ ដែលខណៈពេលនេះ ការធ្វើការពីផ្ទះបានក្លាយជាបទដ្ឋានមួយទៅហើយ។

សម្រាប់ការដាក់ពាក្យស្នើសុំពីអតិថិជនអាជីវកម្មភាគច្រើន ផលិតផលទាំង២នេះ អាចសម្រួលដល់ពួកគេឱ្យទទួលបាននូវប្រសិទ្ធភាពកាន់តែប្រសើរជាងមុន។ សម្រាប់អតិថិជនដែលជាក្រុមហ៊ុនធំៗ យើងក៏កំពុងបង្កើតការគ្រប់គ្រងសាច់ប្រាក់ ខ្សែសង្វាក់ផ្គត់ផ្គង់ ពាណិជ្ជកម្ម និងប្រតិបត្តិការផលិតផលហិរញ្ញវត្ថុដែលនឹងត្រូវដាក់ឱ្យដំណើរការនាពេលអនាគត។

សម្រាប់សេវាធនាគារអាជីវកម្ម គោលដៅរបស់យើង គឺកសាងប្រព័ន្ធអេកូធនាគារឌីជីថល ជាមួយប្រព័ន្ធឌីជីថល និងឧបករណ៍ឌីជីថលដែលមានឥទ្ធិពលជាងមុន ដើម្បីតភ្ជាប់ និងលើកកម្ពស់អតិថិជនដែលជួយក្នុងការពង្រឹងសមត្ថភាពឌីជីថល ការច្នៃប្រឌិតគំរូអាជីវកម្ម និងបទពិសោធន៍សេវាកម្មកាត់បន្ថយចំណាយប្រតិបត្តិការ និងហានិភ័យ ពង្រឹងការប្រកួតប្រជែងទីផ្សារ ដើម្បីសម្រេចឱ្យបាននូវការអភិវឌ្ឍគុណភាពប្រកបដោយចីរភាព។

Q តើអ្វីជាចំណុចសំខាន់ៗនៃកម្មវិធីថ្មីនេះ ហើយតើកម្មវិធីនេះនឹងផ្តល់បទពិសោធន៍នៃការទូទាត់កាន់តែងាយស្រួល ដល់អតិថិជនរបស់លោកយ៉ាងដូម្តេច?

កម្មវិធី PRINCE Merchant App ផ្តល់ឱ្យអតិថិជនរូបវន្តបុគ្គលនូវឧបករណ៍គ្រប់គ្រងការគិតលុយតាមអនឡាញ ដែលអនុញ្ញាតឱ្យអាជីវករអាចគ្រប់គ្រងក្រុមហ៊ុនជំនួសគ្នាបាន ស្របតាមតម្រូវការអាជីវកម្មរបស់ពួកគេ និងកំណត់រចនាសម្ព័ន្ធអ្នកគ្រប់គ្រងសាខា និងបុគ្គលិកគិតលុយ។

អ្នកអាចទាញយក QR កូដ សម្រាប់ការទូទាត់ដោយខ្លួនឯង ហើយដាក់នៅក្នុងទីតាំងដែលត្រឹមត្រូវ។ អ្នកគិតលុយអាចបង្កើតលេខ QR កូដ តាមពេលវេលាជាក់ស្តែង ដើម្បីជួយសម្រួលដល់ការទូទាត់ និងការបញ្ជាក់របស់អតិថិជន។

ទាំងអ្នកទទួល និងអ្នកបង់ប្រាក់អាចទទួលបានព័ត៌មានទូទាត់ និងទទួលប្រាក់បានភ្លាមៗ ហើយអ្នកគិតលុយ អាចសាកសួរ និងគ្រប់គ្រងព័ត៌មាននៃប្រវត្តិប្រតិបត្តិការ សម្រាប់ការផ្សៀងផ្ទាត់ និងរបាយការណ៍ហិរញ្ញវត្ថុ។

វិធីទូទាត់តាមអនឡាញរបស់យើង ក៏នឹងត្រូវដាក់ដំណើរការនាពេលឆាប់ៗ នេះផងដែរ ដែលអាចជួយឱ្យអាជីវករយល់ដឹងពីអាជីវកម្មអនឡាញ និងក្រៅបណ្តាញអ៊ីនធឺណិត។

លោក ហ៊ាន់ សុរចនា
ប្រធាននាយកប្រតិបត្តិធនាគារ ព្រីនស៍

ដោយមានជំនួយពីកម្មវិធីនេះ យើងអាចយល់ដឹងអំពី ការធ្វើអាជីវកម្មឆ្លងកាត់ធនាគារ និងសូម្បីតែឆ្លងប្រទេស ដើម្បីជួយដល់អាជីវករក្នុងការបង្កើនចំនួនអតិថិជន និងបង្កើនប្រាក់ចំណូលរបស់ពួកគេ។ បន្ថែមលើនេះ ការទូទាត់តាម QR កូដ អាចជួយកាត់បន្ថយ ហានិភ័យនៃការឆ្លងមេរោគ ទាំងអាជីវករ និងអតិថិជនរបស់ពួកគេ ហើយវាជួយកុំឱ្យប៉ះពាល់ដោយផ្ទាល់ជាមួយសាច់ប្រាក់ ដែលជាប្រភពនៃការចម្លងមេរោគមួយដែរ។

Q តើប្រព័ន្ធឌីជីថលនៃវិស័យធនាគារបុគ្គលរបស់លោកកំពុងវិវឌ្ឍន៍យ៉ាងដូចម្តេច? តើមានគម្រោងថ្មីត្រៀមដាក់ចេញដែរឬទេ?

ចាប់តាំងពីធនាគារ ព្រីនស៍ បានសម្ពោធជាផ្លូវការនូវផលិតផលធនាគារឌីជីថលរបស់ខ្លួន «PRINCE Mobile» នៅខែតុលា ឆ្នាំ២០១៩ កម្មវិធីនេះត្រូវបានកែលម្អជាបន្តបន្ទាប់ជាមួយនឹងមុខងារ និងផលិតផលកាន់តែល្អប្រសើរ និងបទពិសោធអ្នកប្រើប្រាស់កាន់តែប្រសើរ ហើយត្រូវបានវាយតម្លៃថាជា «ធនាគារឌីជីថលដែលមានការរីកចម្រើនលឿនបំផុត»។

ជាមួយលក្ខណៈពិសេសបច្ចុប្បន្នដែលយើងមាននៅក្នុងកម្មវិធីទូរស័ព្ទ PRINCE Mobile អតិថិជនអាចចូលទៅប្រើគណនីធនាគាររបស់ពួកគេបានយ៉ាងងាយស្រួល និងអាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុបានជាច្រើនប្រភេទ ដូចជាការផ្ទេរប្រាក់ក្នុងស្រុកបានភ្លាមៗ តាមរយៈកម្មវិធីទូទាត់បាគង និងប្រព័ន្ធរំលែលផេ ការទូទាត់វិក្កយបត្រ ការទូទាត់ប្រាក់តាម QR កូដ ស្នើសុំកម្ចី និងដាក់ប្រាក់បញ្ញើ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទ និងមុខងារជាច្រើនទៀត។

ក្នុងពេលឆាប់ៗនេះ យើងនឹងដាក់ឱ្យដំណើរការមុខងារថ្មីមួយទៀត ដូចជា រង្វាន់ពិន្ទុព្រីនស៍ ការទូទាត់តាមរយៈអនឡាញ បំណុលឥណទាន និងការផ្ទេរប្រាក់ឆ្លងប្រទេស។ ទាំងនេះនឹងបន្តធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធវេទិកាធនាគារឌីជីថល និងបង្កើនសមត្ថភាពសេវាកម្មហិរញ្ញវត្ថុបន្តិចម្តងៗ ទៅដល់ដៃគូសហការ។

Q ជាមួយនឹងការកើនឡើងនៃសេវាកម្មធនាគារឌីជីថលនៅទូទាំងពិភពលោក វិស័យនេះក៏ត្រូវបានគេមើលឃើញថាបានពើបប្រទះនឹងការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។ តើហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យារបស់ធនាគារមានសុវត្ថិភាពកម្រិតណាដើម្បីចៀសវាងការវាយប្រហារតាមអ៊ីនធឺណិតនេះ?

ប្រតិបត្តិការប្រកបដោយសុវត្ថិភាព និងស្ថិរភាព គឺជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍន៍អាជីវកម្មធនាគារ ជាពិសេសគឺធនាគារឌីជីថល។ យើងបានចំណាយដើមទុនយ៉ាងច្រើនក្នុងការវិនិយោគលើសន្តិសុខព័ត៌មានជារៀងរាល់ឆ្នាំ ដើម្បីតាមដានការវាយលុក និងការពារហានិភ័យ និងបណ្តាញកសាងប្រព័ន្ធស្តាប់ត្យកម្មសន្តិសុខព័ត៌មានពហុវិមាត្ររបស់យើង។

បើនិយាយអំពីការអភិវឌ្ឍន៍ទេពកោសល្យ ប្រព័ន្ធបច្ចេកវិទ្យា និងប្រតិបត្តិការ គឺយើងក៏កំពុងពង្រឹងឥតឈប់ឈរ។ ការផ្តល់ដំណោះស្រាយកាត់បន្ថយហានិភ័យ និងប្រព័ន្ធការពារសុវត្ថិភាពស្ថ័យប្រវត្តិមានប្រសិទ្ធភាពកម្រិតណា ការវិភាគនិងការកែសម្រួលការត្រួតពិនិត្យ ដែលមានស្រាប់ក៏ត្រូវបានយកចិត្តទុកដាក់ខ្លាំងប៉ុណ្ណោះដែរ ដើម្បីធានាថាការវាយប្រហារថ្មីៗនិងការគំរាមកំហែងតាមអ៊ីនធឺណិតនិងអាចត្រូវបានកាត់បន្ថយយ៉ាងមានប្រសិទ្ធិភាព។ ដំណោះស្រាយធនាគារឌីជីថលរបស់យើងត្រូវបានបង្កើតឡើងក្នុងគោលដៅតែមួយគឺផ្តល់ជូននូវសេវាកម្មធនាគារប្រកបដោយសុវត្ថិភាពដល់អតិថិជនរបស់យើង។

ព័ត៌មានលម្អិតអានតទៅគេហទំព័រ
WWW.POSTKHMER.COM/SPECIAL-REPORT

អតិថិជនធនាគារឌីជីថលអាចរីករាយនឹងបទពិសោធន៍ឌីជីថលកាន់តែប្រសើរ។

អតិថិជនអាចទូទាត់នៅតាមដៃគូ PRINCE Pay 5000+ កន្លែងទូទាំងប្រទេស ជាមួយនឹងប្រម៉ូសិនពិសេសៗជាច្រើន។

ធនាគារ ព្រីនស៍ បង្កើនសមត្ថភាពធនាគារឌីជីថល បន្ថែម ដើម្បីគាំទ្រអតិថិជនពីចម្ងាយរួមទាំងអាជីវកម្ម

រយៈពេល២ឆ្នាំកន្លងមកនេះ ជំងឺរាតត្បាតកូវីដ១៩ ពិតជាបានជំរុញឱ្យការប្រើប្រាស់ឌីជីថលមានច្រើន នៅទូទាំងប្រទេស សម្រាប់ប្រជាជនទាំងអស់នៅកម្ពុជា ជាពិសេសអ្នកដែលកើតក្នុងសម័យឌីជីថល យុវជនដែលប្រើប្រាស់ស្មាតហ្វូន នៅគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងវីរុសនេះ ប្រជាជនបានចាប់ផ្តើមជៀសវាងការចេញទៅក្រៅផ្ទះ ហើយចាប់ផ្តើមពឹងផ្អែកលើវេទិកាឌីជីថលសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃ ដូចជាការទិញទំនិញតាមអនឡាញ ការប្រើសេវាកម្មដឹកជញ្ជូន ការបំពេញការងារពីផ្ទះ និងការគ្រប់គ្រងហិរញ្ញវត្ថុពីចម្ងាយជាដើម។

ក្នុងនាមជាធនាគារឌីជីថលដែលមានការរីកចម្រើនលឿនបំផុតមួយនៅក្នុងប្រទេស ធនាគារ ព្រីនស៍ មានសមត្ថភាពខ្ពស់ក្នុងការផ្តល់ជូននូវបណ្តាញធនាគារឌីជីថលជាច្រើន ដូចជាធនាគារចល័ត ការទូទាត់តាមប្រព័ន្ធឌីជីថល ម៉ាស៊ីន ATM/CDM ដើម្បីផ្តល់នូវសេវាកម្មដែលមានគុណភាពល្អបំផុតដល់អតិថិជននៅក្នុងប្រព័ន្ធដែលមានភាពងាយស្រួល និងមានសុវត្ថិភាព។

ក្នុងអំឡុងពេលនៃជំងឺរាតត្បាតបច្ចុប្បន្ន វាពិតជាពិបាកណាស់សម្រាប់មនុស្សជាច្រើនដែលមិនមានកម្មវិធីធនាគារឌីជីថលនៅលើទូរស័ព្ទដៃរបស់ពួកគេ។ ពួកគេត្រូវប្រើប្រាស់សាច់ប្រាក់ ដោយផ្ទាល់សម្រាប់ការចំណាយប្រចាំថ្ងៃ ហើយវាជាហានិភ័យមួយនៃការឆ្លងមេរោគតាមរយៈការប្រើប្រាស់សាច់ប្រាក់ផ្ទាល់។ ការទូទាត់ដោយមិនប្រើសាច់ប្រាក់ នឹងកាន់តែងាយស្រួលនៅពេលដែលអ្នកមានកម្មវិធី PRINCE Mobile®។

វាអាចជួយសម្រួលដល់ការគ្រប់គ្រងហិរញ្ញវត្ថុប្រចាំថ្ងៃរបស់អតិថិជន ការទូទាត់ដោយមិនប្រើសាច់ប្រាក់ និងការផ្ទេរប្រាក់ដោយសុវត្ថិភាព និងរលូន។ អតិថិជនអាចចូលទៅប្រើប្រាស់គណនីរបស់ពួកគេបានជាប្រចាំថ្ងៃ ហើយក៏អាចធ្វើប្រតិបត្តិការចម្រុះតាមបែបឌីជីថល ដូចជាការបើកគណនីថ្មី ការដាក់ប្រាក់បញ្ញើមានកាលកំណត់ ទូទាត់តាមរយៈ QR កូដ ការទូទាត់វិក្កយបត្រ ការផ្ទេរប្រាក់នៅក្នុងស្រុកតាមរយៈ ប្រព័ន្ធ NCS, ប្រព័ន្ធរីធែលផេ, សេវាទូទាត់រហ័ស និងសេវាទូទាត់បាគង, កាតស្នើប័ណ្ណម៉ាស្ទ័រកាត និងវីសាតាមអនឡាញ និងមុខងារពិសេសជាច្រើនទៀត។

អតិថិជននឹងទទួលបានការជូនដំណឹងតាមពេលវេលាជាក់លាក់ទាក់ទងនឹងការទូទាត់វិក្កយបត្រ ឬប្រតិបត្តិការទាំងអស់ដែលពួកគេបានធ្វើពេញមួយថ្ងៃ ជាមួយពេលវេលា កាលបរិច្ឆេទនិងទីកន្លែងជាក់លាក់ តាមរយៈការទូទាត់តាមប័ណ្ណ និង QR កូដ។ ដោយមានអាជីវករជាដៃគូជាង ៥០០០ កន្លែងនៅទូទាំងប្រទេសនៅតាមទីផ្សារនានា អតិថិជនរបស់យើងអាចធ្វើការទូទាត់ដោយគ្មានសាច់ប្រាក់យ៉ាងងាយស្រួលដោយប្រើកម្មវិធី PRINCE Pay ហើយថែមទាំងអាចរីករាយជាមួយនឹងការទទួលបានប្រាក់ត្រឡប់វិញរហូតដល់ ៣០ដុល្លារ ប្រចាំខែ។

អ្វីដែលកាន់តែពិសេសសម្រាប់ការធ្វើបច្ចុប្បន្នភាពលើកម្មវិធី PRINCE Mobile ® ដែលនឹងចេញក្នុងពេលឆាប់ៗនៅដើមខែកក្កដា គឺការបង្កើតគណនីអ៊ីព្រីនស៍® និងលេខគណនីពិសេស។ គណនីអ៊ីព្រីនស៍® គឺជាគណនីធនាគារអេឡិចត្រូនិក ដែលអនុញ្ញាតឱ្យអតិថិជនថ្មីបើកគណនីធនាគារបានភ្លាមៗពីចម្ងាយជាមួយធនាគារ ព្រីនស៍ តាមរយៈកម្មវិធី PRINCE Mobile®។

អតិថិជនអាចទទួល និងផ្ទេរប្រាក់បានភ្លាមៗនៅក្នុងធនាគារ និងទៅកាន់ធនាគារក្នុងស្រុកដ៏ទៃទៀតអាចទូទាត់វិក្កយបត្រ ទូទាត់តាម QR កូដ អាចរីករាយជាមួយការផ្តល់ជាច្រើន ពីធនាគារ ព្រីនស៍ ទៀតផង។ មុខងារថ្មីមួយទៀតនៃការដាក់បង្ហាញថ្មីនេះ គឺលេខគណនីពិសេស។ លក្ខណៈពិសេសនៃមុខងារនេះអនុញ្ញាតឱ្យអតិថិជនកំណត់យកលេខគណនីតាមជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ ដោយមិនចាំបាច់ចូលទៅកាន់សាខាធនាគារនោះឡើយ។ វាអាចជាលេខពិសេសណាមួយដែលពួកគេចង់បានធ្វើជាលេខគណនីរបស់ពួកគេ។

នៅក្នុងការបង្ហាញថ្មីនេះ ធនាគារក៏នឹងសម្ពោធមុខងារ Prince Rewards Points នៅលើកម្មវិធី PRINCE Mobile ដែលអតិថិជនអាចទទួលបានរង្វាន់ជាពិន្ទុ តាមរយៈការអញ្ជើញមិត្តភក្តិឱ្យចុះឈ្មោះប្រើប្រាស់កម្មវិធី PRINCE Mobile និងតាមរយៈយុទ្ធនាការជាច្រើនទៀត។ ជាមួយរង្វាន់ជាពិន្ទុនេះ អ្នកអាចប្តូរដោយបញ្ចូលកាតទូរស័ព្ទ តាមកម្មវិធី PRINCE Mobile និងនៅតាមហាងអាជីវករដែលជាដៃគូរបស់ PRINCE Pay សម្រាប់ការទូទាត់របស់អ្នក។

ធនាគារ ព្រីនស៍ បានបោះជំហានមួយទៀត ដើម្បីណែនាំកម្មវិធីធនាគារចល័តថ្មីចំនួនពីរ ដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់អតិថិជនអាជីវកម្មរបស់ខ្លួន។

កម្មវិធី PRINCE Mobilebiz® និង PRINCE Merchant® គឺជាកម្មវិធីធនាគារអាជីវកម្មដែលនឹងដាក់ឱ្យប្រើប្រាស់នាពេលខាងមុខនេះ ដែលធនាគារ ព្រីនស៍ មានបំណងពង្រីកការគាំទ្រផ្នែកឌីជីថលដល់អតិថិជន និងដៃគូអាជីវកម្មរបស់ខ្លួន។

ជាមួយបច្ចេកវិទ្យាឌីជីថលដ៏ទំនើបមានសុវត្ថិភាព និងបទពិសោធរបស់អ្នកប្រើប្រាស់ កម្មវិធីទាំងពីរនេះប្រាកដណាស់នឹងជួយដល់ម្ចាស់អាជីវកម្មក្នុងការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ពួកគេឱ្យកាន់តែមានប្រសិទ្ធភាព និងងាយស្រួល។ កម្មវិធីទាំងនេះនឹងអាចប្រើបានទាំងលើប្រព័ន្ធទូរស័ព្ទ iOS និង Android។

ដើម្បីស្វែងយល់បន្ថែមអំពីផលិតផល និងការផ្តល់ជូនពិសេសរបស់ធនាគារ ព្រីនស៍ សូមទាក់ទងទៅទូរស័ព្ទលេខ 1800 20 8888 ឬចូលទៅគេហទំព័រ www.prince-bank.com.kh៕ ■

ធនាគារ ព្រីនស៍ បានណែនាំពីកម្មវិធីធនាគារចល័តថ្មីចំនួនពីរ ដែលត្រូវបានរចនាឡើងយ៉ាងពិសេសសម្រាប់អតិថិជនអាជីវកម្មរបស់ខ្លួន។

សេវាកម្មធនាគារឌីជីថលរបស់ធនាគារ ភីភីស៊ីប៊ែង គឺដើម្បីបម្រើអតិថិជននៅក្នុងអំឡុងពេលវេលាដែលកំពុងមានជំងឺរាតត្បាត

កើនឡើងប្រមាណ២២ភាគរយនៃប្រតិបត្តិការឌីជីថលតាមរយៈកម្មវិធីទូរស័ព្ទ PPCBank Mobile App **និងកាតវីសា**

កម្មវិធីទូរស័ព្ទ PPCBank Mobile App **ជួយអតិថិជនបួនពីប្រតិបត្តិការសាច់ប្រាក់បែបប្រពៃណីទៅប្រតិបត្តិការបែបឌីជីថល។** Supplied

ធនាគារ ភីភីស៊ីប៊ែង បានពង្រីកសេវាកម្មធនាគារឌីជីថលរបស់ខ្លួនដោយដាក់ឱ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រងកាតថ្មីដែលផ្តល់ឱ្យអតិថិជននូវលទ្ធភាពសេវាកម្មធនាគារប្រកបដោយភាពងាយស្រួលនិងរលូន។ ដំណោះស្រាយនៃសេវាកម្មធនាគារឌីជីថលដែលផ្តោតលើសេវាកម្មគ្មានការប៉ះពាល់ (contactless services) បានក្លាយជាសេវាកម្មកាន់តែងាយស្រួលក្នុង អំឡុងពេលផ្ទុះឡើងជំងឺកូវីដ ១៩ ក្នុងសហគមន៍ ដែលវិធានការគម្លាតសង្គមត្រូវបានប្រកាន់ខ្ជាប់។

ប្រព័ន្ធនេះអនុញ្ញាតឱ្យអតិថិជនគ្រប់គ្រងកាតរបស់ពួកគេតាមរយៈកម្មវិធីទូរស័ព្ទ PPCBank Mobile App របស់ធនាគារភីភីស៊ីប៊ែង ហើយវាក៏រួមបញ្ចូលមុខងារដកប្រាក់រៀលនៅតាមម៉ាស៊ីន ATM របស់ធនាគារផងដែរ។

លក្ខណៈពិសេសមួយចំនួនត្រូវបានដាក់ឱ្យដំណើរការ ដូចជា ឲ្យអតិថិជនអាចប្រើកាតរបស់ខ្លួនតាមរយៈកម្មវិធីទូរស័ព្ទ (គ្មានកូដ PIN បណ្តោះអាសន្ន កាត់បន្ថយលទ្ធភាពនៃការលួចបន្លំ) បង្កើតលេខកូដសម្ងាត់ផ្ទាល់ខ្លួន ដែលអាចបិទ/បើកកាត និងកំណត់ប្រតិបត្តិការតាមប្រព័ន្ធឌីជីថល ដោយមិនចាំបាច់ទៅកាន់សាខារបស់ធនាគារដោយផ្ទាល់ ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងវីរុស។

ការដាក់ឱ្យប្រើប្រាស់ការទូទាត់ប័ណ្ណវីសា Contactless ធ្វើឱ្យអតិថិជនមានភាពងាយស្រួលក្នុងការទិញទំនិញតាមអនឡាញ មិនថាទិញនៅក្នុងស្រុកឬពីក្រៅប្រទេស គឺគ្មានការរំខានណាមួយក្នុងអំឡុងពេលបិទខ្ទប់ដើម្បីការពារជំងឺឆ្លង។

នៅក្នុងការជំរុញដល់ម្ចាស់អាជីវកម្មក្នុងការដាក់ឲ្យប្រើប្រាស់ម៉ាស៊ីនឆូតកាត POS របស់ខ្លួន ធនាគារភីភីស៊ីប៊ែងបានទទួលពានរង្វាន់ពីក្រុមហ៊ុន Visa លើ«Leadership in Growth of Active Terminal 2020»។ ការទូទាត់អាចត្រូវបានបញ្ចប់រួចរាល់ដោយគ្រាន់តែប៉ះលើម៉ាស៊ីនឆូតកាតនេះនៅក្នុងចម្ងាយអតិបរមា៥សង្ទីម៉ែត្រពីម៉ាស៊ីនឆូតកាត។ វិធីសាស្ត្រនេះផ្តល់នូវសុវត្ថិភាពសម្រាប់ទាំងអ្នកទិញនិងអ្នកលក់។

Cardless Cash (ការដកប្រាក់ដោយគ្មានប័ណ្ណ) បានផ្តល់មធ្យោបាយមួយទៀតក្នុងការផ្ទេរប្រាក់និងទូទាត់ប្រាក់ឆាប់រហ័ស។ ពីកម្មវិធីទូរស័ព្ទ PPCBank Mobile App អតិថិជនអាចផ្ទេរប្រាក់ទៅនរណាម្នាក់សូម្បីតែអ្នកដែលគ្មានគណនីធនាគារដោយគ្រាន់តែវាយបញ្ចូលលេខទូរស័ព្ទរបស់អ្នកទទួលនិងចំនួនទឹកប្រាក់ជាការស្រេច។ អ្នកទទួលអាចដកសាច់ប្រាក់នៅតាមម៉ាស៊ីន ATM របស់ធនាគារ ភីភីស៊ីប៊ែង ណាមួយ ដោយប្រើលេខកូដផ្ញើតាមសារ SMS ។ ហើយប្រតិបត្តិការនេះគឺធ្វើឡើងដោយមិនគិតថ្លៃសេវាកម្មអ្វីទាំងអស់។

លើសពី ‘Cardless Cash’

ការស្កេននិងបង់ប្រាក់ដែលត្រូវបានគេស្គាល់ថា«mobilePAY»អនុញ្ញាតឱ្យអតិថិជនប្រើការស្កេន QR កូដសម្រាប់ការទូទាត់តាមឌីជីថល នៅតាមហាងលក់ទំនិញដែលជាអតិថិជនរបស់ភីភីស៊ីប៊ែង។ ខណៈមុខងារផ្សេងទៀតដូចជាការទូទាត់ថ្លៃទឹកភ្លើងក៏មានផងដែរ។

កម្មវិធីទូរស័ព្ទ PPCBank Mobile App ទទួលបានការពេញនិយមកាន់តែខ្លាំងឡើងពីសំណាក់អតិថិជនចាប់តាំងពីអំឡុងពេល «ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ» មកម្លេះ ក្នុងការប្រើប្រាស់សេវាបង់ទឹក ភ្លើង និងការផ្ទេរប្រាក់តាមរយៈ«cardless cash» ដោយងាយស្រួលនិងមិនគិតថ្លៃ។ ការកាត់បន្ថយទំនាក់ទំនងដោយផ្ទាល់ជាមួយអ្វីៗដែលមានចន្លោះទូលំទូលាយ ដូចជារូបិយប័ណ្ណ បានបង្ហាញថាវាជាមធ្យោបាយដ៏ល្អបំផុតមួយក្នុងការការពារប្រឆាំងនឹងការឆ្លងជំងឺកូវីដ។

ធនាគារ ភីភីស៊ីប៊ែង ក៏បានជួយលើកកម្ពស់អតិថិជនរបស់ខ្លួន ក្នុងអំឡុងពេលជំងឺរាតត្បាតនេះដែរ ដោយបានពង្រីកមធ្យោបាយទូទាត់ដោយប្រើប្រព័ន្ធ «បាគង» ដែលត្រូវបានបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា។

អតិថិជនអាចផ្ទេរនិងអាចទទួលសាច់ប្រាក់បានភ្លាមៗទៅធនាគារក្នុងស្រុកណាមួយ ដែលជាសមាជិកនៃប្រព័ន្ធទូទាត់«បាគង»។ ភីភីស៊ីប៊ែងក៏បានផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការដាក់ពាក្យស្នើសុំប្រាក់កម្ចីអាជីវកម្មឬកម្ចីផ្ទាល់ខ្លួនដោយអាចបំពេញទម្រង់ពាក្យស្នើសុំកម្ចីតាមអនឡាញនៅលើគេហទំព័ររបស់ធនាគារ ហើយវិធីនេះគឺជួយសន្សំពេលវេលាធ្វើដំណើរទៅកាន់សាខាធនាគារ។

ដើម្បីជួយដល់សហគ្រាសខ្នាតតូចនិងមធ្យមដែលជួបបញ្ហាសាច់ប្រាក់ក្នុងអំឡុងពេលបិទខ្ទប់ មជ្ឈមណ្ឌលសហគ្រាសធុនតូចនិងមធ្យម របស់ភីភីស៊ីប៊ែង ចំនួន២ បូករួមទាំងសេវាបម្រើអតិថិជនអនឡាញត្រូវបានផ្តល់ជូន ដើម្បីជួយដល់ក្រុមហ៊ុននិងម្ចាស់សហគ្រាសដែលមានតម្រូវការ។

គម្រោង CSR

ទោះបីមានភាពតានតឹងនិងបញ្ហាប្រឈមជាច្រើនបានកើតឡើង ដែលបង្កដោយជំងឺរាតត្បាតក្តី ក៏ធនាគារ ភីភីស៊ីប៊ែង ជឿជាក់ថាក្តីមេត្តាគឺជាអ្វីដែលតែងតែធ្វើឱ្យយើងចេះជួយគ្នា។ ដោយដឹងអំពីតម្រូវការរបស់អ្នកដែលមានការខ្វះខាតជាងពួកយើង គម្រោង CSR របស់ភីភីស៊ីប៊ែង គឺជាចំណុចស្នូលរបស់យើង ក្តីមេត្តានេះក៏ជាអ្វីដែលរួបរួមយើងទាំងអស់គ្នា។

ធនាគារ ភីភីស៊ីប៊ែង បានឧបត្ថម្ភដល់ការសម្ពាតដីសហគមន៍ ផ្តល់លទ្ធភាពដល់ប្រជាជន ជួយលើកកម្ពស់គុណភាពជីវិតរបស់ពួកគេតាមរយៈការធ្វើកសិកម្មដោយគ្មានការភ័យខ្លាច។ សូមជួយជនរួមជាតិខ្មែរនៅថ្ងៃនេះតាមរយៈកម្មវិធីទូរស័ព្ទ PPCBank Mobile App។ យើងនឹងបរិច្ចាគ ១០០ភាគរយនៃកាបរិច្ចាគសរុបដែលបានទទួល។

សហគមន៍ដែលបានរងផលប៉ះពាល់ជាយូរទស្សវត្សន៍មកហើយ ពីការគម្រាមកំហែងនៃគ្រាប់មីននៅភាគខាងជើងខេត្តសៀមរាបក៏ស្ថិតនៅចំណុចស្នូលនៃគម្រោង CSR របស់ធនាគារកាលពីឆ្នាំមុនមក។

ភីភីស៊ីប៊ែងបានចាប់ផ្តើមយុទ្ធនាការអង្គាសថវិកា«APOPO Fundraising Campaign» ក្នុងគោលបំណងជួយបោសសម្អាតផ្ទៃដីចំនួន៥ហិកតានៅត្រឹមចុងឆ្នាំ២០២១។ ធនាគារសង្ឃឹមថា កិច្ចខិតខំប្រឹងប្រែងនេះនឹងជួយធ្វើឱ្យប្រទេសកម្ពុជាកាន់តែកៀកទៅដល់គោលដៅសម្រាប់កម្ពុជាគ្មានគ្រាប់មីននៅត្រឹមឆ្នាំ២០២៥ ដោយជឿជាក់ថា«ធ្វើការរួមគ្នាគ្មានអ្វីដែលមិនអាចទៅរួចនោះឡើយ»។

ភីភីស៊ីប៊ែងសង្ឃឹមថាប្រជាកសិករនឹងអាចប្រើប្រាស់ដីបង្កបង្កើនផលប្រកបដោយសុវត្ថិភាព គ្មានភាពភ័យខ្លាច និងបង្កើនផលិតភាពធ្វើស្រែចម្ការលើដីស្រែរបស់ខ្លួន ដែលជួយសំរួលដល់ជីវភាពរស់នៅរបស់ពួកគេ។

ឆ្នាំនេះច្បាស់ណាស់គឺជាឆ្នាំមួយដ៏លំបាក ប៉ុន្តែធនាគារ ភីភីស៊ីប៊ែងនៅតែមានសុទិដ្ឋិនិយមថាប្រទេសកម្ពុជានឹងអាចឆ្លងផុតគ្រាដ៏លំបាកនេះ នឹងកាន់តែរឹងមាំជាងមុន។ យើងកំពុងសម្លឹងមើលការវិវឌ្ឍដ៏ល្អប្រសើរនៅពាក់កណ្តាលឆ្នាំ២០២១ នេះ ហើយជានាដល់អតិថិជនថា ជាមួយនឹងបច្ចេកវិទ្យាថ្មៃប្រឌិតថ្មីរបស់យើង ពួកគេនឹងទទួលបានសេវាកម្មកាន់តែប្រសើរដើម្បីជានាថាសេវាកម្មហិរញ្ញវត្ថុគឺមានសុវត្ថិភាព និងមានភាពងាយស្រួលបំផុត៕ ■

មុខងារ contactless cards **របស់ភីភីស៊ីប៊ែងទទួលបានការពេញនិយមកាន់តែខ្លាំងពីអតិថិជន។**

គម្រោង CSR **មួយរបស់ភីភីស៊ីប៊ែងគឺជួយសម្អាតមីននៅតំបន់ជនបទនៃប្រទេសកកម្ពុជា។**

ខេមអេដពង្រីកអាជីពការងារនៅក្នុងវិស័យហិរញ្ញវត្ថុនិងធនាគារ

សិក្សានៅខេមអេដ និស្សិតនឹងទទួលបានអ្វីពិសេសលើសពីការរំពឹងទុក។ Supplied

វិទ្យាស្ថានខេមអេដប៊ីហ្សនេស្សស្គូល ដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ លើការបណ្តុះបណ្តាលជំនាញ គណនេយ្យ និង ហិរញ្ញវត្ថុ កំពុងផ្តល់នូវជម្រើសដ៏ល្អបំផុតសម្រាប់សិស្សានុសិស្ស ដែលកំពុងស្វែងរកការសិក្សាលើជំនាញទាំងនេះ។

ដោយមានការគាំទ្រពីសមាជិកនៃស្ថាប័នអន្តរជាតិល្បីៗ ខេមអេដទទួលបានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងចំណោមនិយោជក និងនិស្សិត ចំពោះការផ្តល់ការអប់រំផ្នែកហិរញ្ញវត្ថុប្រកបដោយគុណភាពដែលឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យអាជីវកម្ម។

វិទ្យាស្ថានខេមអេដ គឺផ្តល់ការបណ្តុះបណ្តាលទៅលើជំនាញគណនេយ្យ ហិរញ្ញវត្ថុ សវនកម្ម និងធុរៈកិច្ច និងទទួលស្គាល់ដោយក្រសួងអប់រំយុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

វិទ្យាស្ថាន ខេមអេដ គឺជាវិទ្យាស្ថានដែលមានការទទួលស្គាល់ខ្ពស់នៅក្នុងទីផ្សារការងារ រួមជាមួយថ្នាលបណ្តុះបណ្តាលដែលប្រកបដោយគុណភាព គុណវុឌ្ឍិ និងការទទួលស្គាល់ទាំងក្នុងស្រុក និងលើឆាកអន្តរជាតិ ដូចជាការទទួលស្គាល់ពីសមាគមគណនេយ្យករជំនាញ (ACCA) នៅចក្រភពអង់គ្លេស វិទ្យាស្ថាន Chartered Financial Analyst (CFA) និង Accreditation Council for Business Schools and Programs នៅសហរដ្ឋអាមេរិក និង ASEAN University Network នៅអាស៊ី។ ហើយក៏ទទួលបានការទទួលស្គាល់ផ្នែកគ្រប់គ្រងកម្រិតស្តង់ដារ ISO 9001:2015 ដោយ Guardian Independent Certification ដែលបានចុះបញ្ជីនៅចក្រភពអង់គ្លេស ផងដែរ។

ទន្ទឹមនឹងនេះដែរ ការសិក្សាថ្នាក់បរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ (BA+CAT) នៅវិទ្យាស្ថានខេមអេដ សិស្សានុសិស្សនឹងទទួលបានអ្វីដែលពិសេស និងលើសពីការរំពឹងទុកជាច្រើនទៀតដូចជា៖

• ការសិក្សាក្នុងរយៈពេល ៤ឆ្នាំ ប៉ុន្តែនិស្សិតនឹងទទួលបាននូវសញ្ញាបត្រ២ក្នុងពេលតែមួយ រួមមានសញ្ញាបត្របរិញ្ញាបត្រគណនេយ្យ និងហិរញ្ញវត្ថុ ដែលទទួលស្គាល់ដោយសញ្ញាបត្រអ្នកបច្ចេកទេសផ្នែកគណនេយ្យអន្តរជាតិ (CAT) ពីចក្រភពអង់គ្លេស ដែលទទួលស្គាល់រហូតដល់ ១៨៣ប្រទេសលើពិភពលោក។ លើសពីនេះនិស្សិតក៏អាចទទួលបាននូវសញ្ញាបត្រជំនាញផ្នែកពន្ធដារ និងសញ្ញាបត្រជំនាញផ្នែកច្បាប់ពាណិជ្ជកម្មផងដែរ។

• ការបណ្តុះបណ្តាលត្រូវបានផ្អែកលើស្តង់ដារគណនេយ្យ IFRS និងបំពេញតាមតម្រូវការអប់រំ IFAC ដែលជាហេតុធ្វើឱ្យនិស្សិតដែលបញ្ចប់ការសិក្សា ឬកំពុងសិក្សា អាចបន្តការសិក្សានៅក្រៅប្រទេសដោយងាយស្រួល និងមានភាពរលូនល្អ។

• ការបណ្តុះបណ្តាលដោយសាស្ត្រាចារ្យដែលមានទាំងបទពិសោធន៍ និងជំនាញច្បាស់លាស់ មកពីបណ្តាប្រទេសមួយចំនួនដូចជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស សិង្ហបុរី ម៉ាឡេស៊ី ហ្វីលីពីន និងហុងកុង ជាដើម ដែលសាស្ត្រាចារ្យទាំងអស់ត្រូវជ្រើសរើស និងវាយតម្លៃលើការបង្រៀនតាំងពីពេលចាប់ផ្តើមសិក្សារហូតបញ្ចប់ថ្នាក់សិក្សានីមួយៗ ដើម្បីធានានូវគុណភាពក្នុងការបណ្តុះបណ្តាលខ្ពស់។

• ការសិក្សាដោយផ្តោតលើទ្រឹស្តី អនុវត្ត និងជំនាញច្បាស់លាស់ រួមជាមួយការដកស្រង់នូវបទពិសោធន៍ជាក់ស្តែង តាមរយៈការចូលរួមក្លឹបសិក្សា និងការទស្សនៈកិច្ចទៅកាន់បណ្តាក្រុមហ៊ុនផ្សេងៗទាំងក្នុងប្រទេស និងក្រៅប្រទេស បានធ្វើឱ្យនិស្សិតជាច្រើនទទួលបានទាំងចំណេះដឹងជំនាញនិងបទពិសោធន៍ច្បាស់លាស់។

• ការសិក្សាលើថ្នាក់បរិញ្ញាបត្រជំនាញមួយ តែនិស្សិតអាចបម្រើការងារបានច្រើនប្រភេទដូចជា៖ គណនេយ្យករ ហេរញ្ញិក សវនករ អ្នកគ្រប់គ្រងអាជីវកម្ម អ្នកគ្រប់គ្រងស្តុក មន្ត្រីផ្នែកពន្ធដារ អ្នកវិភាគអាជីវកម្ម និងការិនីយោគ អ្នកប្រឹក្សាផ្នែកពន្ធដារ និងអាជីវកម្ម ព្រមទាំងផ្នែកផ្សេងៗជាច្រើនទៀត។ ហើយវិទ្យាស្ថានបានផ្តល់នូវផ្នែកជួយរកការងារជូននិស្សិតទាំងអស់ និស្សិតកាន់តែមានភាពងាយស្រួលក្នុងការស្វែងរកការងារទាំងនៅក្រុមហ៊ុនអន្តរជាតិ និងស្ថាប័នក្នុងស្រុក តាមក្តីស្រមៃរបស់ខ្លួន។

វិទ្យាស្ថាន ខេមអេដ គឺជាកន្លែងដ៏ល្អបំផុតដើម្បីចាប់ផ្តើម។ សម្រាប់ព័ត៌មានលម្អិតសូមចូលទៅកាន់គេហទំព័រ www.cam-ed.com ឬទំនាក់ទំនងមកកាន់ទូរស័ព្ទ 023 986 522 / 012 618 988។ ■

សេដ្ឋកិច្ចឌីជីថលរបស់ប្រទេសកម្ពុជា

ប្រទេសកម្ពុជាមានមូលដ្ឋានគ្រឹះដ៏ល្អសម្រាប់កសាងសេដ្ឋកិច្ចឌីជីថលរបស់ខ្លួន ដោយប្រជាជនវ័យក្មេងមានចំនួនច្រើន និងការប្រើប្រាស់អ៊ីនធើណិតមានកម្រិតខ្ពស់។

> **ប្រជាជនវ័យក្មេងមានចំនួនច្រើនជាងគេបំផុតមួយនៅក្នុងតំបន់**
ចំនួនប្រជាជនកម្ពុជាមានប្រមាណ១៦លាននាក់ ក្នុងនោះអាយុជាមធ្យមគឺ២៥ឆ្នាំ។

> **វិស័យសេវាកម្មហិរញ្ញវត្ថុដែលកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស**
ជាមួយប័ណ្ណឥណពន្ធចំនួន ២,៦៥ លានប័ណ្ណ នៅឆ្នាំ២០១៩ ដែលតួលេខនេះបានកើនឡើងទ្វេដងក្នុងរយៈពេល៥ឆ្នាំ។

> **អត្រាប្រើប្រាស់ទូរសព្ទ័ចល័តខ្ពស់**
ប្រទេសកម្ពុជាមានអត្រាប្រើប្រាស់ទូរស័ព្ទចល័តខ្ពស់បំផុតមួយនៅលើពិភពលោក ដែលមានចំនួន ២០,៨ លានស៊ីមកាត ឬស្មើនឹង ១២៤% នៃចំនួនប្រជាជនសរុប។

> **អត្រាប្រើប្រាស់ស្មាតហ្វូនខ្ពស់**
ទូរស័ព្ទស្មាតហ្វូនមានចំនួន១០,៧លានគ្រឿងត្រូវបានភ្ជាប់អ៊ីនធើណិត។ អត្រាទិន្នន័យមានតម្លៃថោកបំផុតមួយនៅក្នុងតំបន់គឺ១ដុល្លារប្រើបាន10GB កម្រិតសេវា 4G និង 3G ដែលគ្របដណ្តប់ប្រមាណ៨០% និង៨៥% នៃចំនួនប្រជាជន។

> **ការប្រើប្រាស់បណ្តាញសង្គម**
គិតត្រឹមពាក់កណ្តាលឆ្នាំ២០២០ អ្នកប្រើប្រាស់ហ្វេសប៊ុកមានចំនួន ១០,៨ លានគណនី។

> **ឱកាសនៅក្នុងផ្នែក MSME**
ប្រទេសកម្ពុជាមានសហគ្រាសធុនតូចបំផុត តូច និងមធ្យម (MSMEs) ប្រមាណ ៥០០,០០០ ក្នុងនោះ ៩៥% ជាអាជីវកម្មក្រៅផ្លូវការដែលមិនបានចុះបញ្ជី។ មានតែអាជីវកម្មមួយចំនួនតូចប៉ុណ្ណោះបានចុះបញ្ជីត្រឹមត្រូវ៖ តូចបំផុត (០,០២%) តូច (៣,៨៩%) មធ្យម (២៤,១១%)៕

10.8m
ចំនួនអ្នកប្រើប្រាស់ហ្វេសប៊ុកនៅកម្ពុជា (65% នៃចំនួនប្រជាជន)

2.65m
ចំនួនបណ្ណឥណ្ណពន្ធ (ទ្វេរដងនៃចំនួនកាលពី៥ឆ្នាំមុន)

124%
ចំនួនប្រើប្រាស់ទូរសព្ទ័ចល័ត (២០,៨ លានស៊ីមកាត)

80%
ការគ្របដណ្តប់នៃកម្រិតសេវា 4G នៃចំនួនប្រជាជន (3G គ្របដណ្តប់ 85%)

16.6m
ចំនួនប្រជាជនកម្ពុជា (៥៣% អាយុក្រោម២៥ឆ្នាំ)

7.1%
អត្រាកំណើន GDP ក្នុងឆ្នាំ២០១៩ (GDP $ ២៦,៩ ៣ន់លាន) និងផលិតផលក្នុងស្រុកសរុបក្នុងមនុស្សម្នាក់ ១ ៦២៣ ដុល្លារ ក្នុងឆ្នាំ២០១៩

21
ចំនួនស្ថាប័នសេវាកម្មបង់ប្រាក់ (ភ្នាក់ងារ ២៧ ៩៧៤ និង ១៥ ០៣៧ អាជីវករ)

5.22m
គណនី E-wallet (គិតត្រឹមចុងឆ្នាំ២០១៩) កំណើន ៦៤% ក្នុងរយៈពេលមួយឆ្នាំ

> 17
ចំនួនកន្លែងធ្វើការរួម (ជាង៥០០តុ)

> 6
ក្រុមហ៊ុនវិនិយោគរួម (វិនិយោគបច្ចេកវិទ្យា)

> 300
ចំនួនក្រុមហ៊ុនបច្ចេកវិទ្យាចាប់ផ្តើមថ្មីសកម្ម

> 30
ចំនួននៃការវិនិយោគចាប់ផ្តើមថ្មី

ប្រភព៖ Mekong Strategic Partners